**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ ;...០៣២..ប្រ.ក....ប.ស្ថ

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ «ផ្កាវ» នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ស្ថិតក្នុងភូមិផ្កាវ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

៣៖៤

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម០១២/០៦១៨/ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៧៤អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ «ព្រៃឡង់»
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.** ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ«**ផ្កាវ**» នៃដែនជម្រកសត្វព្រៃ«ព្រៃឡង់» ស្ថិតក្នុងភូមិផ្កាវ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

**ប្រការ២.** សហគមន៍តំបន់ការពារធម្មជាតិ «**ផ្កាវ**» នៃដែនជម្រកសត្វព្រៃ«ព្រៃឡង់»មានផ្ទៃដីទំហំ **១១១៩ ហិកតា** ដូចមានផែនទីជាឧបសម្ព័ន្ធកំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកា ដូចក្នុងតារាងខាងក្រោម៖



អគារមរតកតេជោ ផ្លូវលេខ៥០៣ ភ្ជាប់ស្ពានអាកាសសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 567431 | 1505429 | 10 | 562283 | 1502368 |
| 2 | 566012 | 1505390 | 11 | 562427 | 1501966 |
| 3 | 564775 | 1505216 | 12 | 563888 | 1501902 |
| 4 | 563174 | 1504877 | 13 | 564085 | 1503274 |
| 5 | 561952 | 1504605 | 14 | 565999 | 1503789 |
| 6 | 561886 | 1503517 | 15 | 566102 | 1504021 |
| 7 | 561866 | 1503035 | 16 | 566643 | 1504067 |
| 8 | 561702 | 1502364 | 17 | 566702 | 1504187 |
| 9 | 562008 | 1502270 | 18 | 567606 | 1504687 |

**ប្រការ៣.** ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«ផ្កាវ»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤.** សហគមន៍តំបន់ការពារធម្មជាតិ **«ផ្កាវ»** នៃដែនជម្រកសត្វព្រៃ «ព្រៃឡង់» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។ សហគមន៍តំបន់ការពារធម្មជាតិ **«ផ្កាវ»** ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន។

**ប្រការ៥.** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកគ្រប់អគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង នាយកតំបន់ដែនជម្រកសត្វព្រៃ«ព្រៃឡង់» និងសហគមន៍តំបន់ការពារធម្មជាតិ **«ផ្កាវ»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

សាយ សំអាល់

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តស្ទឹងត្រែង
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិផ្អាវ ក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់
# ភូមិសាស្ត្រភូមិផ្អាវ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ផ្ទៃដី១១១៩ហិកតា

ភ្ជាប់ជូន : ប្រកាសលេខ ០៣២ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន




| Id | Labal | Coor_X | Coor_Y |
|---|---|---|---|
| 1 | A | 567431 | 1505429 |
| 2 | B | 566012 | 1505390 |
| 3 | C | 564775 | 1505216 |
| 4 | D | 563174 | 1504877 |
| 5 | E | 561952 | 1504605 |
| 6 | F | 561886 | 1503517 |
| 7 | G | 561866 | 1503035 |
| 8 | H | 561702 | 1502364 |
| 9 | I | 562008 | 1502270 |
| 10 | J | 562283 | 1502368 |
| 11 | K | 562427 | 1501966 |
| 12 | L | 563888 | 1501902 |
| 13 | M | 564085 | 1503274 |
| 14 | N | 565999 | 1503789 |
| 15 | O | 566102 | 1504021 |
| 16 | P | 566643 | 1504067 |
| 17 | Q | 566702 | 1504187 |
| 18 | R | 567606 | 1504687 |

Map Coordinate System
Unit: meter
System: UTM, Zone 48
Datum: WGS 1984